ពាក្យបុរាណហៅបាតុភូតយប់និងថ្ងៃមានរយៈពេលស្មើគ្នា

កន្ទងមកប្រជាជនខ្មែរមិនសូវចាប់អារម្មណ៍នឹងបាតុភូតដែលយប់ និងថ្ងៃមានរយៈពេលស្មើគ្នានោះទេ ដ្បិតមិនមានជាកិច្ចពិធីអ្វីនៅចំថ្ងៃនោះ។ ក្នុងរវាង១ទសវត្សក្រោយមកនេះ មនុស្សម្នាចាប់អារម្មណ៍នឹងព្រឹត្តិការណ៍ជាខ្លាំង ដ្បិតមានការផ្សព្វផ្សាយទូលំទូលាយអំពីដំណើរគោចររបស់ព្រះអាទិត្យរះចំកំពូលកណ្តាលប្រាសាទអង្គរវត្ត។ បាតុភូតនេះ គេច្រើនតែស្គាល់ពាក្យហៅថា «សមរាត្រី» ប៉ុន្តែខ្មែរពីបុរាណមានពាក្យហៅបាតុភូតនេះរួចស្រេចទៅហើយ។ នៅក្នុងអត្ថបទខ្លីនេះ យើងពិនិត្យមើលតែលើការប្រើប្រាស់ពាក្យហៅព្រឹត្តិការណ៍នេះពីបុរាណកាលមកពុំនិយាយអំពីបាតុភូតតារាសាស្ត្រឡើយ។

ពាក្យ «សមរាត្រី» ឬពេលខ្លះឃើញមានប្រើជា «សមភាពរាត្រី» បង្កើតឡើង ដើម្បីប្រែសង្ត្រង់ទៅនឹងពាក្យបារាំង «équinoxe» និងពាក្យអង់គ្លេស «equinox» ដែលពាក្យក្នុងភាសាទាំងពីរនេះ មានប្រភពចេញមកពីភាសាឡាតាំងថា «aequinoctium»។ ពាក្យក្នុងភាសាឡាតាំងនេះ បង្កើតឡើងដោយពាក្យ «aequus» មានន័យថា «សម ស្មើ» + «nox» មានន័យថា «រាត្រី យប់»។ ពាក្យ «សមរាត្រី» នេះ បង្កើតដោយគណៈកម្មាធិការជាតិអចិន្ត្រៃយ៍ខេមរយានកម្ម ដែលបានចុះផ្សាយនៅក្នុងសទ្ទានុក្រមខេមរយានកម្ម (បារាំង - ខ្មែរ) ចេញផ្សាយដោយវិទ្យាស្ថានជាតិខេមរយានកម្ម នាឆ្នាំ១៩៧៣។[1]

យ៉ាងនេះក្តី នៅក្នុងឆ្នាំ១៩៦២ លោក តិប យក់ និងថាវ គន្ធ ដែលជាសមាជិកក្នុងគណៈកម្មការវប្បធម៌ បានប្រែពាក្យបារាំង «équinoxe» ថា «អយនកាល» និងបញ្ជាក់សេចក្តីពន្យល់ថាជាកាលក្នុងរដូវដែលមានវេលាថ្ងៃនិងយប់ស្មើគ្នា គឺនៅថ្ងៃទី២១ ឬ២២ ខែមីនា និងថ្ងៃទី២២ ឬ២៣ ខែកញ្ញា)។[2] ពាក្យប្រែនេះ គឺផ្អែកទៅលើពាក្យ «អយនកាល» នៅក្នុងវចនានុក្រមខ្មែរ ដែលពន្យល់ថាជាសុរិយគតិកាលក្នុងរដូវដែលមានវេលាថ្ងៃនិង

[1] សទ្ទានុក្រមខេមរយានកម្ម ១៩៧៣។

[2] តិប យក់ និង ថាវ គន្ធ ១៩៦២។

យប់ស្មើគ្នា។[៣] បើយើងមើលពាក្យ «អយន» នៅក្នុងភាសាសំស្ក្រឹតវិញ មានន័យថាវិថីគោចរ របស់ព្រះអាទិត្យនៅខាងជើងនិងខាងត្បូងអេក្វាទ័រ រយៈពេលកន្ទុះឆ្នាំ ចំណុចដែលមាន រយៈពេលយប់និងថ្ងៃស្មើគ្នា ឬព្រះអាទិត្យគោចរទៅខាងត្បូងឬខាងជើងបំផុត[៤] ដែលត្រូវ នឹងពាក្យបារាំងអង់គ្លេសថា «Solstice»[៥]។ ដូច្នេះពាក្យ «អយនកាល» ក៏ពុំមានន័យចំនឹង ពាក្យ បារាំង «équinoxe» និងពាក្យអង់គ្លេស «equinox» ទាំងស្រុងនោះដែរ។

បើយោងតាមប្រភពសិលាចារឹកខ្មែរបុរាណវិញ ខ្មែរបានប្រើប្រាស់ពាក្យហៅបាតុភូត នេះ តាមភាសាសំស្ក្រឹតថា «វិឃុវ» ដែលសរសេរសង៏មកអក្សរសព្ទថ្ងៃជា «វិសុវ» និងអាច សរសេរតាមលំនាំនៃការវិវត្តភាសាខ្មែរជា «ពិសុព»។ ភស្តុតាងអំពីការប្រើប្រាស់ពាក្យនេះ ឃើញមានវត្តមានចាស់ជាងគេនៅក្នុងសិលាចារឹកទួលស្វែង K.១៤៨៩ ស្ថិតនៅក្នុង សម័យមុនអង្គរ មានចុះកាលបរិច្ឆេទនៅមហាសកពជឆ្នាំ៥៦៣ ត្រូវនឹងគ្រិស្តសកពជឆ្នាំ ៦២១ រកឃើញនៅក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម។ ក្នុងសិលាចារឹកនេះ បានបង្ហាញពី ការថ្វាយដង្វាយសម្រាប់ធ្វើកិច្ចពិធីនាវេលាដែលថេរវេលាយប់និងថ្ងៃស្មើគ្នា ដោយប្រើពាក្យ សម្គាល់បាតុភូតនោះថា «វិឃុវគ្រហ» ឬសរសេរជាតាមបែបខ្មែរបច្ចុប្បន្នជា «វិសុវគ្រាស / ពិសុពគ្រាស»។ ដូចគ្នាដែរ នៅក្នុងសលាចារឹកប្រាសាទកំពែងធំ (ឬកំពែងណៃ) K.៣៧៤ មានកាលបរិច្ឆេទនៅមហាសកពជ៩៦២ ត្រូវនឹងគ្រឹស្តសកពជ១០៤២ បានប្រើពាក្យ «វិឃុវសង្ក្រាន្ត» (វិសុវសង្ក្រាន្ត) សំដៅវេលាដែលមានដំណើរគោចរព្រះអាទិត្យដល់ចំណុច ដែលមានរយៈពេលយប់និងថ្ងៃស្មើគ្នា។ តាមសិលាចារឹកនេះ នៅក្នុងឆ្នាំ១០៤២ បាតុភូត នេះកើតឡើងចំថ្ងៃទី២កើត ខែចៃត្រ។ ពាក្យ «គ្រហ» នេះត្រូវនឹងពាក្យ «គ្រាស» ដែល

---

[៣] សូមមើល វចនានុក្រមខ្មែរ ១៩៦៨។ សេចក្ដីនៅក្នុងសៀវភៅវចនានុក្រមបារាំងខ្មែរ បោះពុម្ពផ្សាយក្នុងឆ្នាំ ១៩៦២ ប្រហែលជាយោងទៅលើវចនានុក្រមខ្មែរ បោះពុម្ពផ្សាយនៅគ្រាទី៤។

[៤] Monier-Williams, 1872។

[៥] ពាក្យនេះនៅក្នុងសទ្ទានុក្រមខេមរយានកម្ម ពុំប្រែមកជាភាសាខ្មែរនោះទេ គឺប្រើប្រាស់វិធីកម្ចីសូរបារាំង មកប្រើជា «សុលស្ទីស»។

យើងប្រើនៅពេលសព្វថ្ងៃ គឺសំដៅដល់ដំណើររបស់ព្រះអាទិត្យឬព្រះចន្ទចូលកាន់ទីតាំងណាមួយ និងច្រើនប្រើជា «ចន្ទ្រគ្រាស» និង «សូរ្យគ្រាស»។ ចំណែកឯពាក្យ «សង្ក្រាន្ត» វិញ ក៏ប្រើសំដៅដល់ដំណើរចេញពីទីតាំងមួយចូលកាន់ទីតាំងមួយដែរ[៦]។ ដូច្នេះ «វិមុវសង្ក្រាន្ត» ក៏សំដៅដល់កាលវេលា ឈានចូលរយៈពេលយប់និងថ្ងៃស្មើគ្នា ដូចនឹង «វិសុវគ្រហ» ដែរ។

នៅក្នុងសិលាចារឹកខ្មែរ បង្ហាញឱ្យយើងដឹងថា នៅពេលមានបាតុភូត «វិសុវ» គឺជាពេលត្រូវធ្វើពិធីបូជាតាមកិច្ចក្នុងព្រហ្មញ្ញសាសនា។ យោងតាមសិលាចារឹកទេពប្រណម្ម K.២៩០ បានសរសេរថា នៅវេលាបុណ្យស្រាទ្ធ ចន្ទ្រគ្រាស សូរ្យគ្រាស និងវិសុវ ត្រូវធ្វើបាយបិណ្ឌឧទ្ទិសដល់បុព្វការី ត្រូវថ្វាយអង្ករចំនួន១ខារី (= ៩៥,៥ គ.ក.) សម្រាប់ធ្វើពិធីតាមចំណាំដែលបានធ្វើកន្ទងមក។ នៅក្នុងសិលាចារឹកប្រាសាទគុកល្វាទេរ K.១៤៦១ ក៏បានបង្ហាញពីអាចារ្យដឹកនាំពិធីត្រូវធ្វើពិធីបូជាថ្វាយព្រះជគន្នាថដោយប្រើថូអាយ៉ៃ និងថូវទ្ធ៌ណ៌ ដោយរីករាយនៅថ្ងៃសង្ក្រាន្ត និងថ្ងៃវិសុវ អាចារ្យនោះនឹងសម្រេចបាននូវក្តីប្រាថ្នាយ៉ាងប្រាកដពុំក្លាយជាប្រការដទៃឡើយ។

ដូច្នេះជាសរុបមក ខ្មែរបុរាណបានប្រើពាក្យ «វិសុវ» ឬ «ពិសុព» ហៅវេលាដែលមានរយៈពេលយប់និងថ្ងៃស្មើគ្នា។ នៅវេលានោះ ត្រូវមានកិច្ចពិធីបូជាផ្សេងៗតាមទំនៀមក្នុងព្រហ្មញ្ញសាសនា ដែលក្នុងនោះមានការបូជាបាយបិណ្ឌផងដែរ។ ប្រហែលដោយសារការផ្ទាស់ប្តូរពីព្រហ្មញ្ញសាសនា មកជាពុទ្ធសាសនាវេរវាទវិញ ដែលពុំតម្រូវឱ្យមានកិច្ចពិធីអ្វីនៅថ្ងៃនោះ ទើបខ្មែរហាក់ភ្លេចបាតុភូតនិងពាក្យហៅបាតុភូតនេះ ទើបក្រោយមកនៅក្នុងវចនានុក្រមខ្មែរ ប្រើពាក្យ «អយនកាល» ដែលពុំត្រូវចំនឹងបាតុភូតនោះទាំងស្រុង។ ឯខេមរយានកម្ម ប្រែពន្ធាត់សងពាក្យត្រង់ពីបារាំងអង់គ្លេសមកជា «សមរាត្រី» វិញ។

[៦] សូមអានបន្ថែម៖ https://ams.com.kh/khmercivilization/detail/6839 និង https://youtu.be/gdEKbS9W1r4 ។

ឯកសារយោង

ติบ យ៉ប់ និង ថាវ គន្ធ. ១៩៦២. វចនានុក្រមបារាំង-ខ្មែរ / Dictionnaire Français-Khmer។ ពុទ្ធសាសនបណ្ឌិត្យ. ១៩៦៨. វចនានុក្រមខ្មែរភាគ២. ពុទ្ធសាសនបណ្ឌិត្យ។ វិទ្យាស្ថានខេមរយានកម្ម. ១៩៧៣. សទ្ទានុក្រមខេមរយានកម្ម។

Monier-Williams, M. (1872). *A Sanskṛit-English dictionary etymologically and philologically arranged: With special reference to Greek, Latin, Gothic, German, Anglo-Saxon, and other cognate Indo-European languages*. Clarendon Press.

បញ្ជីរូបភាព

រូបថតថ្ងៃរះនៅប្រាសាទអង្គរ (ប្រភពរូប៖ លីម ប៊ុនហុង)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

រូបថតថ្ងៃរះនៅប្រាសាទអង្គរ (ប្រភពរូបៈ លីម ប៊ុនហុង)



សំណៅផ្ដិតសិលាចារឹកទួលស្វែង K.១៦៨៩ (ប្រភពរូបៈ ហ៊ុន ឈុនតេង)

អត្ថបទដោយៈ ហ៊ុន ឈុនតេង



សំណៅសិលាចារឹកប្រាសាទកំពែងណៃ K.៣៧៤

អត្ថបទដោយ៖ ហ៊ុន ឈុនតេង